# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមិថុនា និងប្រចាំឆមាសទី ១ ឆ្នាំ២០២០ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ

ថ្ងៃសុក្រ ៤ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃសុក្រ ៤រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ នៅសាលប្រជុំសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផល ប្រមូលចំណូលពន្ធប្រចាំខែមិថុនា និងប្រចាំឆមាសទី១ឆ្នាំ២០២០ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមរបស់ ឯកឧត្តម-លោកជំទាវអគ្គនាយករង លោកប្រធាន-អនុប្រធាននាយកដ្ឋាន សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ។

ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ឯកឧត្តម គង់ វិបុល បានបង្ហាញថាក្នុងខែមិថុនា ឆ្នាំ២០២០ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ របស់អគ្គនាយកដ្ឋាន

ពន្ធដារ) មានចំនួន ៨០៩,១៩ប៊ីលានរៀល (ប្រមាណជា ១៩៩,៨០លានដុល្លារអាមេរិក) ស្មើនឹង ៧,០១% នៃផែនការប្រចាំឆ្នាំ។

សម្រាប់ឆមាសទី ១ ឆ្នាំ ២០២០ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ) មានចំនួន ៦ ៨២០,៤៨ ប៊ីលានរៀល (ប្រមាណជា ១ ៦៨៤,០៧ លានដុល្លារអាមេរិក) ស្មើនឹង ៥៩,០៩% នៃផែនការប្រចាំឆ្នាំ ធៀបនឹងចំណូលពន្ធ-អាករ ក្នុងរយៈពេលដូចគ្នា ឆ្នាំ២០១៩ ឃើញថាកើនឡើងចំនួន ៧៣៥,៨២ ប៊ីលានរៀល (ប្រមាណជា ១៨១,៦៨ លានដុល្លារអាមេរិក) ស្មើនឹង ១២%។ គួរបញ្ជាក់ផងដែរថា ក្នុងឆមាសទី១ ឆ្នាំ២០២០ ចំណូលពីប្រភេទពន្ធ ០២ នៅរក្សាកំណើនគួរឱ្យកត់សម្គាល់ក្នុងនោះ អាករលើតម្លៃបន្ថែមចំនួន ១ ៣៨៥,០៦ប៊ីលានរៀល ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ កើនឡើង ៦៣,៧៩ ប៊ីលានរៀល ប្រមាណ ៤,៨៣% និងពន្ធលើប្រាក់ចំណូលចំនួន ២ ៧១០,១៨ ប៊ីលានរៀល ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ កើនឡើង ៥០៧,២៦ ប៊ីលានរៀល ប្រមាណ ២៣,០៣%។

សម្រាប់ឆ្នាំ២០២០ នេះ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តការប្រមូលចំណូ ល ពន្ធបានគ្រប់តាមផែនការច្បាប់ ចំនួនប្រមាណ ១១ ៥៤៣,៣១ ប៊ីលានរៀល (ប្រមាណ ២ ៨៨៥,៨៣ លានដុល្លារអាមេរិក) អគ្គនាយកដ្ឋានពន្ធដារ នឹងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ថែមទៀតនូវគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ព្រមទាំងដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

- អនុវត្តឱ្យមានប្រសិទ្ធភាព នូវការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ និងពង្រឹងការងារចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីធានាការផ្តល់សេវាឱ្យបានល្អប្រសើរនិងការគ្រប់គ្រងចំណូលពន្ធមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹងការងារចាត់ចែងលិខិតប្រកាស និងជំរុញការអនុវត្តការគ្រប់គ្រងដាក់លិខិតប្រកាស តាមប្រព័ន្ធអនឡាញ (E-Filing) ដោយផ្តល់លទ្ធភាពក្នុងការរៀបចំខ្លួន និងផ្តល់ការបណ្តុះបណ្តាលសមស្របដល់អ្នកជាប់ពន្ធប្រើប្រាស់ប្រព័ន្ធនេះ ឱ្យមានប្រសិទ្ធភាព និងភាពងាយស្រួល
- ពង្រឹងការអនុវត្តការប្រមូលបំណុលពន្ធ និងវិធានការតឹងទារបំណុលពន្ធ ជាពិសេសបំណុលពន្ធធំៗ ដែលមានសក្តានុពល ដោយកំណត់ជាបំណុលអាទិភាព
- ពង្រឹងការធ្វើការសវនកម្ម ដោយពន្លឿនរយៈពេលនៃការធ្វើសវនកម្ម និងបន្តបង្កើនកិច្ចសហប្រតិបត្តិការក្នុងការប្រមូលទិន្នន័យពីគ្រប់ប្រភពនិងស្ថាប័នពាក់ព័ន្ធ
- បន្តនិងខិតខំពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ដែលជាកត្តាសំខាន់ធ្វើឱ្យប្រសើរឡើងនូវវប្បធម៌ពន្ធដារ ក្នុង


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នោះមានការ រៀបចំកម្មវិធី "ពន្ធដារកម្ពុជា" ដោយផ្សព្វផ្សាយ និងជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់ (GDT Facebook Live), សេវាឆ្លើយតបតាមប្រពន្ធទូរស័ព្ទ Call Center 1277, កម្មវិធី GDT Live Chat ជាដើម

- អនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០២០
- បន្តពង្រឹងការគ្រប់គ្រង សហគ្រាសស្នើសុំផ្អាកបណ្តោះអាសន្ន ឬស្នើសុំបើកដំណើរការឡើងវិញ
- បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធិភាព នូវវិធានការអន្តរាគមន៍បន្ទាន់របស់រាជរដ្ឋាភិបាលដើម្បីទ្រទ្រង់វិស័យទេសចរណ៍, វិស័យអាកាសចរ, វិស័យកសិកម្ម និងការចិញ្ចឹមសត្វ, និងវិស័យកាមន្តសាលទូទៅ និងវិធានការអន្តរាគមន៍នានាដើម្បីជំរុញកំណើនសេដ្ឋកិច្ច
- បន្តអនុវត្តវិធានការចាំបាច់នានា ដូចមានកំណត់ក្នុងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០២០ និងយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៩-២០២៣។

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ នៅតាមអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំប្រឹងប្រែងប្រមូលចំណូល ដែលទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ហើយនេះគឺជាជោគជ័យ និងជាសមិទ្ធផលរួម របស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។ ជាមួយគ្នានេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក្រើនរម្លឹក និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់ជាន់ថ្នាក់ ត្រូវយកចិត្តទុកដាក់ថែទាំសុខភាព និងបង្កាទប់ស្កាត់ចំពោះជំងឺផ្លូវដង្ហើមប្រភេទថ្មី Covid-19 និងសូមគោរពជូនពរថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ជួបតែវិបុលសុខ និងសមប្រកបនឹងពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ